Khmer

# សាលាមត្តេយ្យកុមារវ័យតូច សម្រាប់ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន



## ហេតុអ្វីបានជាសាលាមត្តេយ្យមានសារៈសំខាន់?

សាលាមត្តេយ្យជួយរៀបចំកុមារឱ្យទទួលបានជោគជ័យនៅសាលារៀន និងក្នុងជីវិតរស់នៅ។ នៅសាលាមត្តេយ្យ កុមារប្រើការលេងដើម្បីរៀនអំពីភាសា លេខ និងលំនាំ។ ពួកគេក៏រៀនពីរបៀបចុះសម្រុងគ្នាជាមួយអ្នកដទៃ ចែករំលែក ស្តាប់ និងគ្រប់គ្រងអារម្មណ៍របស់ពួកគេផងដែរ។ គ្រូជួយកុមារឱ្យទៅជាចង់ដឹងចង់ឃើញ ច្នៃប្រឌិត និងមានទំនុកចិត្តលើការរៀនសូត្រ។ ការស្រាវជ្រាវបង្ហាញថា ការរៀនសូត្រនៅសាលាមត្តេយ្យពីរឆ្នាំ គឺល្អប្រសើរជាងមួយឆ្នាំ។

## តើសាលាមត្តេយ្យកុមារវ័យតូចគឺជាអ្វី?

សាលាមត្តេយ្យកុមារវ័យតូច ផ្តល់នូវកម្មវិធីសាលាមត្តេយ្យរយៈពេល 15 ម៉ោងក្នុងមួយសប្តាហ៍ដោយឥតគិតថ្លៃ ឬមានតម្លៃទាប សម្រាប់កុមារអាយុ 3 ឆ្នាំដែលមានប្រវត្តិជាជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន។

ការដាក់ពាក្យសុំសម្រាប់ សាលាមត្តេយ្យកុមារវ័យតូច ត្រូវបានធ្វើឡើងដោយសាលាមត្តេយ្យ។ ប្រាក់ឧបត្ថម្ភសាលាមត្តេយ្យកុមារវ័យតូច ត្រូវបានបង់ដោយផ្ទាល់ទៅសាលាមត្តេយ្យ។

## តើកូនរបស់ខ្ញុំមានសិទ្ធិទទួលទេ?

កូនរបស់អ្នកមានសិទ្ធិទទួលប្រសិនបើអ្នក ឬកូនរបស់អ្នក៖

- មានទិដ្ឋាការជនភៀសខ្លួន ឬទិដ្ឋាការមនុស្សធម៌ (humanitarian visa) ឬ
- កំពុងដាក់ពាក្យសុំទិដ្ឋាការជនភៀសខ្លួន ឬទិដ្ឋាការមនុស្សធម៌ ឬ
- មានប័ណ្ណ ImmiCard បច្ចុប្បន្ន ឬផុតកំណត់។

ប្រសិនបើគ្មានការអនុវត្តណាមួយទាំងនេះទេ ប៉ុន្តែអ្នក ឬកូនរបស់អ្នកធ្លាប់ជាជនភៀសខ្លួន ឬអ្នកស្វែងរកសិទ្ធិជ្រកកោន ឬមានបទពិសោធន៍ស្រដៀងគ្នា កូនរបស់អ្នកអាចនៅតែមានសិទ្ធិទទួល។

សូមទាក់ទងមក Department of Education and Training តំបន់របស់អ្នក ដើម្បីសួរអំពីការលើកលែង។ អ្នកក៏អាចសួរអ្នកជំនាញដែលគាំទ្រអ្នក ដើម្បីទាក់ទងមកក្រសួងជំនួសអ្នកផងដែរ។





## តើខ្ញុំចុះឈ្មោះកូនរបស់ខ្ញុំដោយរបៀបណា?

សាលាមត្តេយ្យកុមារវ័យតូច មាននៅក្នុងកម្មវិធីសាលាមត្តេយ្យទាំងអស់ ជាមួយគ្រូដែលមានគុណសម្បត្តិ។ អ្នកអាចចុះឈ្មោះកូនរបស់អ្នក ដោយទាក់ទងមកសាលាមត្តេយ្យដែលនៅជិតអ្នក ឬសាលាសង្កាត់របស់អ្នក។

ប្រាប់សាលាមត្តេយ្យប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់។ ពួកគេអាចប្រើសេវាបកប្រែផ្ទាល់មាត់តាមទូរសព្ទដោយឥតគិតថ្លៃ។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការចុះឈ្មោះ សូមសួរ Department of Education and Training ឬអ្នកវិជ្ជាជីវៈណាម្នាក់ដែលគាំទ្រអ្នក ដូចជា៖

- បុគ្គលិកគាំទ្រ
- បុគ្គលិកពីវប្បធម៌
- គិលានុបដ្ឋាកសុខភាពមាតា និងទារក
- អ្នកសម្របសម្រួលគាំទ្រក្រុមកុមារតូចៗលេងជាមួយគ្នា។

## តើកូនរបស់ខ្ញុំគួរទៅសាលាមត្តេយ្យកុមារអាយុបួនឆ្នាំទេ?

មែនហើយ។ បន្ទាប់ពីសាលាមត្តេយ្យកុមារវ័យតូច កូនរបស់អ្នកមានសិទ្ធិទទួលបានសាលាមត្តេយ្យកុមារអាយុបួនឆ្នាំដោយឥតគិតថ្លៃ ឬមានតម្លៃទាប។ នេះនឹងជួយពួកគេបន្តនូវការអភិវឌ្ឍន៍ភាពរឹងមាំរបស់ពួកគេ។



## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពី សាលាមត្តេយ្យកុមារវ័យតូចនៅឯណា?

- ចូលទៅកាន់គេហទំព័រ education.vic.gov.au ហើយស្វែងរក Early Start Kindergarten ឬ
- ទូរសព្ទទៅការិយាល័យក្រសួងអប់រំ និងបណ្ដុះបណ្ដាល (Department of Education and Training) ក្នុងតំបន់របស់អ្នក។

## ទំនាក់ទំនងការិយាល័យប្រចាំតំបន់

| ការិយាល័យប្រចាំតំបន់ | ទីតាំង |
|---|---|
| តំបន់ខាងជើងឆៀងខាងកើត<br>រដ្ឋ Victoria<br>**1300 333 231** | Benalla<br>Wodonga<br>Wangaratta<br>Seymour<br>Shepparton<br>Glen Waverley |
| តំបន់ខាងជើងឆៀងខាងលិច<br>រដ្ឋ Victoria<br>**1300 338 691** | Bendigo<br>Mildura<br>Swan Hill<br>Coburg<br>Greensborough |
| តំបន់ខាងត្បូងឆៀងខាងកើត<br>រដ្ឋ Victoria<br>**1300 338 738** | Moe<br>Leongatha<br>Warragul<br>Sale<br>Cheltenham<br>Frankston<br>Dandenong |
| តំបន់ខាងត្បូងឆៀងខាងលិច<br>រដ្ឋ Victoria<br>**1300 333 232** | Ararat<br>Ballarat<br>Geelong<br>Horsham<br>Warrnambool<br>Footscray<br>Keilor |

ដើម្បីទទួលបានជំនួយជាភាសារបស់អ្នក៖

- ទូរសព្ទទៅសេវាកម្មជាតិបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS) តាមលេខ 131 450
- ស្នើសុំឱ្យអ្នកបកប្រែទូរសព្ទទៅលេខសម្រាប់តំបន់របស់អ្នក (សូមមើលខាងលើ)
- អ្នកបកប្រែនឹងបន្តនៅជាប់តាមទូរសព្ទ ហើយបកប្រែជូនអ្នក។

KINDERGARTEN
Victorian Government Approved

បោះពុម្ពដោយ Department of Education and Training ទីក្រុងមែលប៊ន ខែមករា ឆ្នាំ 2022© រដ្ឋ Victoria

21-052